ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៦០០ ប្រក. កសក

# ប្រកាស

# ស្តីពី

# ការបង្កើតតំបន់គ្រប់គ្រងដែនជម្រកសុវត្ថិភាពត្រីការ៉ុង
# នៅពាមក្រសោប ខេត្តកោះកុង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួល អគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតតំបន់គ្រប់គ្រងដែនជម្រកសុវត្ថិភាពត្រីកាម៉ុង នៅពាមក្រសោប ខេត្តកោះកុង ដើម្បីការពារ អភិរក្ស និងប្រើប្រាស់ត្រីកាម៉ុងប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយវិស័យជលផលជាតិ។

**ប្រការ២._**

ប្រកាសនេះមានគោលដៅ៖

- ធានាបាននូវប្រព័ន្ធអេកូឡូស៊ីនៃដែនជម្រកសុវត្ថិភាពត្រីកាម៉ុងឱ្យល្អប្រសើរឡើង
- គ្រប់គ្រងផលស្តុកត្រីកាម៉ុងឱ្យមាននិរន្តរភាព
- រួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន។

**ប្រការ៣._**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើដែននេសាទដែលមានផ្ទៃក្រឡាសរុបចំនួន១ ២៨៣ ហិកតា (មួយពាន់ពីររយប៉ែតសិបបីហិកតា) ស្ថិតនៅក្នុងភូមិសាស្ត្រឃុំពាមក្រសោប ស្រុកមណ្ឌលសីមា និងឃុំកោះកាពិ ស្រុកកោះកុង ខេត្តកោះកុង។ ផែនទីនិងនិយាមកានៃដែនជម្រកសុវត្ថិភាពត្រីកាម៉ុងនៅពាមក្រសោប ខេត្តកោះកុង ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤._**

ត្រូវបានហាមឃាត់ការធ្វើនេសាទត្រីកាម៉ុងក្នុងតំបន់ដែនជម្រកសុវត្ថិភាពត្រីកាម៉ុងនៅពាមក្រសោប ខេត្តកោះកុង ចាប់ពីថ្ងៃទី០១ ខែធ្នូ ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងសកម្មភាពធ្វើការពិសោធន៍ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល។

**ប្រការ៥._**

ការគ្រប់គ្រងតំបន់ដែនជម្រកសុវត្ថិភាពត្រីកាម៉ុងនៅពាមក្រសោប ខេត្តកោះកុង ស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលជលផល និងរដ្ឋបាលខេត្តកោះកុង ដែលមានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង ជាសេនាធិការផ្ទាល់ ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍នានា និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំយន្តការគ្រប់គ្រង
- រៀបចំ និងអនុវត្តផែនការគ្រប់គ្រង
- រៀបចំក្រុមល្បាត បំពាក់បរិក្ខារល្បាត និងអនុវត្តសកម្មភាពល្បាត
- កំណត់និងបោះបង្គោលព្រំប្រទល់
- សិក្សាស្រាវជ្រាវបច្ចេកទេស អង្កេតតាមដានលក្ខណៈជីវសាស្ត្រ និងផលស្តុកត្រីកាម៉ុងក្នុងធម្មជាតិ
- អប់រំនិងផ្សព្វផ្សាយដល់ប្រជានេសាទនិងអ្នកពាក់ព័ន្ធផ្សេងៗអំពីសារប្រយោជន៍នៃដែនជម្រកសុវត្ថិភាពត្រីកាម៉ុង
- ស្វែងរកជំនួយនិងកិច្ចសហការពីដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ និងសប្បុរសជននានា ដើម្បីគាំទ្រផ្តល់មូលនិធិទ្រទ្រង់សកម្មភាពគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងដែនសុវត្ថិភាពត្រីកាម៉ុង។

**ប្រការ៦._**

ប្រភពថវិកាសម្រាប់ការងារបង្កើតនិងគ្រប់គ្រងដែនជម្រកសុវត្ថិភាពត្រីកាម៉ុងមានជាអាទិ៍៖

- ថវិកាជាតិ

- ថវិកាដៃគូអភិវឌ្ឍន៍និងវិស័យឯកជននានា
- ជំនួយសប្បុរសជន
- ចំណូលពីប្រភពផ្សេងៗ។

**ប្រការ៧._**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩._**

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកោះកុង
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥០០ប្រក.កសក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការបង្កើតតំបន់គ្រប់គ្រងដែនជម្រកសុវត្ថិភាពត្រីកាម៉ុង នៅពាមក្រសោប ខេត្តកោះកុង




| ដែនជម្រកសុវត្ថិភាព ត្រីកាម៉ុង | |
|---|---|
| អាប់ស៊ីស | អ័រដោនេ |
| ២៨២៣៧៧ | ១២៦៨២៩៤ |
| ២៨១២៨០ | ១២៦៩៩៩២ |
| ២៧៩៦៥០ | ១២៧២២៦៩ |
| ២៧៧២៦៨ | ១២៧១១៧៤ |
| ២៧៧៨១៣ | ១២៧០៣៤៤ |
| ២៧៨២៥៤ | ១២៦៩៩៩២ |
| ២៧៨៧៤៦ | ១២៦៨៥០៤ |
| ២៧៩១៦១ | ១២៦៨៩៧០ |
| ២៨០៣៧២ | ១២៦៧០៣០ |

កំណត់សំគាល់

• ចំនុចព្រំប្រទល់ដែនជម្រកសុវត្ថិភាពផលផល ■ ដែនជម្រកសុវត្ថិភាពត្រីកាម៉ុង ■ ព្រៃកោងកាង ■ ដីគោក ■ សមុទ្រ